# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ១៤៨ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- ធានាប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវរបស់នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈនៃក្រសួងទេសចរណ៍
- បង្កើត និងបង្កើនយន្តការនៃការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងជាសាធារណៈអំពីអត្ថប្រយោជន៍នៃវិស័យទេសចរណ៍ព្រមទាំងជំរុញចលនាទេសចរណ៍ក្នុងស្រុកប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវ
- ធានានូវការគ្រប់គ្រងវិស័យទេសចរណ៍ដោយឈរលើគោលការណ៍នីតិរដ្ឋ។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**ប្រការ ៣.-**

**នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ** ចំណុះអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងជាសេនាធិការឱ្យក្រសួងទេសចរណ៍ ទទួលបន្ទុកការងារគ្រប់គ្រង តាមដាន ត្រួតពិនិត្យ ផ្សព្វផ្សាយ និងជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈអំពីវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុកនិងអប់រំការយល់ដឹងជាសាធារណៈ** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈអំពីវិស័យទេសចរណ៍ដល់សាធារណជន
- ផលិតស្ប៉ត និងឯកសារនានាពាក់ព័ន្ធនឹងទេសចរណ៍ ដើម្បីធ្វើការផ្សព្វផ្សាយ និងជំរុញទេសចរណ៍ក្នុងស្រុកឱ្យកាន់តែទូលំទូលាយ
- រៀបចំ និងផ្សព្វផ្សាយព័ត៌មានអប់រំការយល់ដឹងជាសាធារណៈទាក់ទងនឹងកិច្ចអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព និងទទួលខុសត្រូវ
- គ្រប់គ្រងមណ្ឌលព័ត៌មានទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យ និងតាមដានព័ត៌មានទេសចរណ៍កម្ពុជាដែលធ្វើការផ្សព្វផ្សាយជាសាធារណៈ
- សហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍ក្នុងការជំរុញ និងរៀបចំខ្សែទស្សនកិច្ចតាមគោលដៅទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយផ្នែកផ្សព្វផ្សាយព័ត៌មាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ក្នុងការបញ្ជ្រាបការយល់ដឹងជាសាធារណៈអំពីវិស័យទេសចរណ៍តាមគ្រប់រូបភាព និងគ្រប់មធ្យោបាយ
- សហការអភិវឌ្ឍ ផ្សព្វផ្សាយ និងថែរក្សាគេហទំព័ររបស់ក្រសួងទេសចរណ៍ឱ្យទូលំទូលាយ
- សហការរៀបចំ និងបង្កើតទេសចរណ៍-MICE (ម៉ាយ៖ ទេសចរណ៍បែបប្រជុំ សន្និសីទ និងពិព័រណ៍) និងព្រឹត្តិការណ៍ទេសចរណ៍សំខាន់ៗក្នុងប្រទេស
- សហការជាមួយសមាគមទីភ្នាក់ងារទេសចរណ៍ និងភាគីពាក់ព័ន្ធក្នុងឧស្សាហកម្មទេសចរណ៍ ដើម្បីសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ក្នុងស្រុក
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**ប្រការ ៤.-**

នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ មានការិយាល័យចំណុះចំនួន ០៦(**ប្រាំមួយ**) ដូចខាងក្រោម៖

១-ការិយាល័យអប់រំបញ្ជ្រាបការយល់ដឹងជាសាធារណៈ
២-ការិយាល័យរៀបចំព្រឹត្តិការណ៍ទេសចរណ៍
៣-ការិយាល័យផ្សព្វផ្សាយទេសចរណ៍ក្នុងស្រុក ព័ត៌មានវិទ្យា និងគ្រប់គ្រងព័ត៌មានទេសចរណ៍
៤-ការិយាល័យសិក្សាទីផ្សារទេសចរណ៍ក្នុងស្រុក និងទំនាក់ទំនងសាធារណៈ
៥-ការិយាល័យផលិតកម្ម និងឯកសារផ្សព្វផ្សាយ
៦-ការិយាល័យអភិវឌ្ឍកញ្ចប់ទស្សនកិច្ច។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ ៥.-**

ការិយាល័យនីមួយៗ មានតួនាទី និងភារកិច្ចដូចតទៅ៖

**១-ការិយាល័យអប់រំបញ្ជ្រាបការយល់ដឹងជាសាធារណៈ** មានតួនាទី និងភារកិច្ច៖

- អប់រំបញ្ជ្រាបការយល់ដឹងអំពីគុណប្រយោជន៍នៃវិស័យទេសចរណ៍ក្នុងបរិបទសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន
- ជំរុញចលនាប្រឡងប្រណាំងដែលដាក់ចេញដោយក្រសួងទេសចរណ៍
- រៀបចំកម្មវិធីអប់រំបញ្ជ្រាបការយល់ដឹងអំពីទស្សនទាន"ស្អាត និងបៃតង" ដល់ប្រតិបត្តិករ អាជីវករ កម្មករ និងប្រជាពលរដ្ឋ ព្រមទាំងគោលដៅទេសចរណ៍ សាលារៀន រោងចក្រ ផ្សារ និងទីប្រជុំជនឱ្យបានជាប្រចាំ
- មានសិទ្ធិចុះកិច្ចសន្យាជាមួយប្រព័ន្ធផ្សព្វផ្សាយនានាក្រោយទទួលបានការឯកភាពពីរដ្ឋមន្ត្រី
- រៀបចំអត្ថបទអំណាន និងកម្រងសំណួរ ចម្លើយ អំពីតួនាទីរបស់វិស័យទេសចរណ៍ក្នុងការកសាងសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន
- សហការផលិតកម្មវិធីយល់ដឹងអំពីទេសចរណ៍ជាមួយប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ
- សហការផលិតឯកសារទេសចរណ៍ផ្នែកអប់រំ
- សហការជាមួយភាគីពាក់ព័ន្ធដើម្បីបញ្ចូលកម្មវិធីការយល់ដឹងនិងសារៈប្រយោជន៍នៃវិស័យទេសចរណ៍
- សហការជាមួយគ្រឹះស្ថានអប់រំនានាក្នុងការរៀបចំទស្សនកិច្ចសិក្សាសម្រាប់សិស្ស និស្សិតទៅកាន់គោលដៅទេសចរណ៍។

**២-ការិយាល័យរៀបចំព្រឹត្តិការណ៍ទេសចរណ៍** មានតួនាទី និងភារកិច្ច៖

- សិក្សារៀបចំ និងបង្កើតព្រឹត្តិការណ៍ទេសចរណ៍នៅតាមតំបន់ និងគោលដៅទេសចរណ៍
- រៀបចំគំរូ និងរចនាបថព្រឹត្តិការណ៍ទៅតាមតំបន់ និងគោលដៅទេសចរណ៍ដោយផ្អែកលើទំនៀមទំលាប់ប្រពៃណី និងវប្បធម៌

- សហការរៀបចំគម្រោង និងគ្រប់គ្រងព្រឹត្តិការណ៍ទេសចរណ៍ សន្និសីទ និងពិព័រណ៍នានា
- សហការជាមួយអង្គភាព និងភាគីពាក់ព័ន្ធរៀបចំ និងចូលរួមព្រឹត្តិការណ៍ទេសចរណ៍ សន្និសីទ និងពិព័រណ៍នានា។

**៣-ការិយាល័យផ្សព្វផ្សាយទេសចរណ៍ក្នុងស្រុក ព័ត៌មានវិទ្យា និងគ្រប់គ្រងព័ត៌មានទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- រៀបចំ បង្កើត និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយអំពីសក្តានុពលទេសចរណ៍ក្នុងស្រុកតាមរយៈគេហទំព័រ សារអេឡិចត្រូនិច និងបណ្តាញផ្សព្វផ្សាយសង្គម
- អនុវត្តយុទ្ធនាការឃោសនាផ្សព្វផ្សាយនានាពាក់ព័ន្ធនឹងទេសចរណ៍កម្ពុជា
- ប្រមូល វិភាគ ចងក្រង និងគ្រប់គ្រងព័ត៌មានដែលពាក់ព័ន្ធនឹងទេសចរណ៍កម្ពុជា
- ត្រួតពិនិត្យ ណែនាំការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ក្នុងប្រទេស
- ពិនិត្យ និងតាមដានព័ត៌មានដែលពាក់ព័ន្ធនឹងទេសចរណ៍កម្ពុជាលើប្រព័ន្ធផ្សព្វផ្សាយនានា
- សហការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងស្ថិតិ ទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធនឹងទេសចរណ៍ក្នុងស្រុក
- សហការរៀបចំ បង្កើត និងគ្រប់គ្រងមណ្ឌលព័ត៌មានទេសចរណ៍ទូទាំងប្រទេស
- គ្រប់គ្រងបញ្ជរព័ត៌មាននៅតាមច្រកទ្វារអន្តរជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា
- សហការអភិវឌ្ឍ ផ្សព្វផ្សាយ និងថែរក្សាគេហទំព័ររបស់ក្រសួងទេសចរណ៍
- សហការ ផលិត និងរៀបចំគេហទំព័រផ្សព្វផ្សាយទេសចរណ៍កម្ពុជា
- សហការ និងសម្របសម្រួលការរៀបចំសម្ភារៈផ្សព្វផ្សាយ និងការបោះពុម្ពផ្សាយ រួមមាន ទស្សនាវដ្ដីទេសចរណ៍ ព្រឹត្តិបត្រព័ត៌មាន បណ្ណផ្សព្វផ្សាយព័ត៌មាន ។ល។
- សម្របសម្រួលការផ្តល់ព័ត៌មានទេសចរណ៍ដល់អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយនានា
- សម្របសម្រួលការរៀបចំ និងផលិតឯកសារប្រចាំឆ្នាំស្តីពីសមិទ្ធផលការងារជំរុញទេសចរណ៍ក្នុងស្រុក
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការជំរុញ និងរៀបចំខ្សែទស្សនកិច្ចតាមគោលដៅទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយនឹងមន្ទីរទេសចរណ៍រាជធានី ខេត្តដើម្បីប្រមូលព័ត៌មាន និងស្ថិតិទេសចរជាតិ និងអន្តរជាតិនៅតាមតំបន់ និងគោលដៅទេសចរណ៍នីមួយៗ។

**៤-ការិយាល័យសិក្សាទីផ្សារទេសចរណ៍ក្នុងស្រុក និងទំនាក់ទំនងសាធារណៈ** មានតួនាទី និងភារកិច្ចៈ

- សិក្សាស្រាវជ្រាវ និងធ្វើការវិភាគអំពីស្ថានភាព និងតម្រូវការនៃទីផ្សារទេសចរណ៍ក្នុងស្រុក ដើម្បីរៀបចំយុទ្ធសាស្ត្រទីផ្សារ និងផែនការទាក់ទាញទេសចរណ៍ដើម្បីជំរុញ និងលើកកម្ពស់ចលនាទេសចរណ៍ក្នុងស្រុក
- ប្រមូល និងចងក្រងព័ត៌មានតាមគោលដៅទេសចរណ៍នានាក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយនឹងសមាគមទីភ្នាក់ងារទេសចរណ៍ និងភាគីពាក់ព័ន្ធក្នុងឧស្សាហកម្មទេសចរណ៍ដើម្បីសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ក្នុងស្រុក
- សហការជាមួយនឹងអង្គភាព ផ្នែកឯកជន ភាគីពាក់ព័ន្ធ និងតំណាងទេសចរណ៍នៅបរទេសរៀបចំ និងផ្សព្វផ្សាយខ្សែទស្សនកិច្ចទៅកាន់គោលដៅទេសចរណ៍នានា
- សហការជាមួយនឹងអង្គភាព ផ្នែកឯកជន ភាគីពាក់ព័ន្ធដើម្បីទទួល FAM Trip
- សហការតាមដាន និងត្រួតពិនិត្យនូវលទ្ធផលនៃការផ្សព្វផ្សាយគោលដៅទេសចរណ៍កម្ពុជាលើទីផ្សារអន្តរជាតិតាមរយៈក្រុម FAM Trip
- គ្រប់គ្រងការងាររដ្ឋបាល ទំនាក់ទំនងសាធារណៈ និងសម្របសម្រួលការងាររបស់នាយកដ្ឋាន
- គ្រប់គ្រង និងចរាចរឯកសាររបស់នាយកដ្ឋាន
- សម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា និងផែនការ ត្រួតពិនិត្យ និងវាយតម្លៃរបស់នាយកដ្ឋាន។

**៥-ការិយាល័យផលិតកម្ម និងឯកសារផ្សព្វផ្សាយ** មានតួនាទី និងភារកិច្ចៈ

- ប្រមូល និងចងក្រងរូបភាព និងវីដេអូនៃគោលដៅទេសចរណ៍នានាទូទាំងប្រទេស
- ផលិតស្ប៉ត និងឯកសារផ្សព្វផ្សាយនានាពាក់ព័ន្ធនឹងទេសចរណ៍កម្ពុជា
- ផលិតស្ប៉តនិងឯកសារអប់រំស្តីពីវិស័យទេសចរណ៍ដើម្បីធ្វើឱ្យប្រសើរឡើងនូវផលិតផល និងសេវាកម្មទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំកម្មវិធីប្រកួតប្រជែង និងពិព័រណ៍រូបភាព និងវីដេអូអំពីសក្តានុពលទេសចរណ៍
- រៀបចំផែនការបោះពុម្ពផ្សាយសម្ភារៈទេសចរណ៍តាមតម្រូវការ
- សិក្សាស្រាវជ្រាវ ប្រមូល និងចងក្រងឯកសារផ្សព្វផ្សាយ និងអប់រំដែលអាចធានាបាននូវប្រសិទ្ធភាពក្នុងការងារឃោសនា និងផ្សព្វផ្សាយ
- បោះពុម្ពសម្ភារៈ និងបរិក្ខាផ្សព្វផ្សាយទេសចរណ៍នានា
- សហការរៀបចំសម្ភារៈ និងបរិក្ខាផ្សព្វផ្សាយទេសចរណ៍តាមតម្រូវការភាសា និងទីផ្សារទេសចរណ៍នៅកម្ពុជា។

**៦-ការិយាល័យអភិវឌ្ឍកញ្ចប់ទស្សនកិច្ច** មានតួនាទី និងភារកិច្ចៈ

- សិក្សា និងរៀបចំយន្តការគ្រប់គ្រង និងត្រួតពិនិត្យលើការរៀបចំកញ្ចប់ទស្សនកិច្ចក្នុងស្រុក
- សិក្សាស្រាវជ្រាវ និងរៀបចំបង្កើតបណ្តាទស្សនកិច្ច និងបណ្តាវិស្សមកាល
- សហការជាមួយនឹងស្ថាប័នរដ្ឋ ឯកជន សមាគមទីភ្នាក់ងារទេសចរណ៍ និងភាគីពាក់ព័ន្ធក្នុងឧស្សាហកម្មទេសចរណ៍ក្នុងការជំរុញនិងរៀបចំខ្សែទស្សនកិច្ចតាមគោលដៅទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយនឹងអង្គភាព ផ្នែកឯកជន ភាគីពាក់ព័ន្ធ ធ្វើការរៀបចំនិងផ្សព្វផ្សាយកញ្ចប់ទស្សនកិច្ចទៅកាន់គោលដៅទេសចរណ៍នានានៅក្នុងប្រទេស
- សហការជាមួយនឹងមន្ទីរទេសចរណ៍រាជធានី ខេត្ត ចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យពាក់ព័ន្ធនឹងតំបន់ទេសចរណ៍ដែលមានសក្តានុពលនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយនឹងភាគីពាក់ព័ន្ធក្នុងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ប្រតិបត្តករទេសចរណ៍ និងភាគីពាក់ព័ន្ធក្នុងឧស្សាហកម្មលើការបង្កើតកញ្ចប់ទស្សនកិច្ចដែលមានភាពទាក់ទាញ និងឆ្នៃប្រឌិត។

**ប្រការ ៦.-**

ការិយាល័យនីមួយៗ ចំណុះឱ្យនាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ មានតួនាទី និងភារកិច្ចៈ

- គ្រប់គ្រងបញ្ជីវត្តមាន និងតាមដានការអនុវត្តរបស់មន្ត្រីរាជការ និងបុគ្គលិកទាំងក្នុង និងក្រៅក្របខណ្ឌ និងការកសាងសមត្ថភាពរបស់ការិយាល័យ
- ធ្វើកំណត់ហេតុប្រជុំដែលពាក់ព័ន្ធនឹងការងារទទួលខុសត្រូវរបស់ខ្លួន
- រៀបចំគម្រោងផែនការសកម្មភាពការងារ និងថវិកាចំណាយផ្សេងៗ និងប្រចាំឆ្នាំជូនប្រធាននាយកដ្ឋាន
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធាននាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ